**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:..៩៦..អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគផ្ទៃដីទំហំ ៥.០០០ហិកតា ស្ថិតក្នុងតំបន់ឧទ្យានជាតិបុទុមសាគរ ភូមិសាស្ត្រស្រុកគីរីសាគរ និងស្រុកកោះកុង ខេត្តកោះកុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៥.០០០ហិកតា ស្ថិតក្នុងតំបន់ឧទ្យានជាតិបុទុមសាគរ ស្រុកបុទុមសាគរ ខេត្តកោះកុង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៥.០០០ហិកតា ក្នុងតំបន់ឧទ្យានជាតិបុទុមសាគរ ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកកោះកុង និងស្រុកគីរីសាគរ ខេត្តកោះកុង ក្រោមលក្ខខណ្ឌ ជួល ឬសម្បទាន ដើម្បីធ្វើការវិនិយោគ អភិវឌ្ឍន៍លើវិស័យទេសចរណ៍ធម្មជាតិ ដូចមានក្នុងផែនទី និងនិយាមកា ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា២នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣.-**

អនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩ ស្ដីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៥.០០០ហិកតា ស្ថិតក្នុងតំបន់ឧទ្យានជាតិបុទុមសាគរ ស្រុកបុទុមសាគរ ខេត្តកោះកុង និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**

សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ ៖-អនុក្រឹត្យកំណត់តំបន់លេខ.......ចុះថ្ងៃទី......ខែ......ឆ្នាំ២០១៧
-អនុក្រឹត្យអនុបយោគលេខ.......ចុះថ្ងៃទី......ខែ......ឆ្នាំ២០១៧

**ផែនទីទីតាំងដីវិនិយោគអភិវឌ្ឍន៍លើវិស័យទេសចរណ៍ធម្មជាតិ របស់ក្រុមហ៊ុន JW Cambodia Eco Holidays**

**ស្ថិតក្នុងឧទ្យានជាតិបុទុមសាគរ ភូមិសាស្ត្រស្រុកគីរីសាគរ និងស្រុកកោះកុង ខេត្តកោះកុង លើផ្ទៃដីទំហំ ៥000 ហិកតា**




| Id | N | Coor x | Coor y |
|---|---|---|---|
| 1 | A | 301865 | 1246024 |
| 2 | B | 304505 | 1244248 |
| 3 | C | 304232 | 1247052 |
| 4 | D | 303686 | 1249264 |
| 5 | E | 304851 | 1250093 |
| 6 | F | 306344 | 1250075 |
| 7 | G | 307173 | 1248182 |
| 8 | H | 307983 | 1249929 |
| 9 | I | 310432 | 1249365 |
| 10 | J | 310632 | 1247580 |
| 11 | K | 311752 | 1246279 |
| 12 | L | 312171 | 1244339 |
| 13 | M | 310004 | 1243511 |
| 14 | N | 308648 | 1242810 |
| 15 | O | 305980 | 1242501 |
| 16 | P | 303113 | 1242992 |
| 17 | Q | 302029 | 1244467 |
| 18 | R | 300992 | 1245641 |
| 19 | S | 299719 | 1247264 |
| 20 | T | 300112 | 1247699 |

**សញ្ញាសំគាល់**

- ចំណុចនិយាមការ
- ទីតាំងដីវិនិយោគ
- ផ្លូវជាតិ
- ផ្លូវលំ
- ស្ទឹង. អូរ
- ព្រំប្រទល់តំបន់ការពារធម្មជាតិ

